# សេចក្ដីថ្លែងការណ៍រួម

## យើងត្រូវការតំណាងរាស្ត្រស្ត្រីយ៉ាងតិច ៣០% សម្រាប់នីតិកាលទី៥

យើងខ្ញុំជាក្រុមការងារស្ត្រីដើម្បីទាំងអស់គ្នា ដែលរួមមានក្រុមនិស្សិត សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ២៥ មានការខកចិត្តយ៉ាងខ្លាំងចំពោះការថយចុះនៃចំនួនស្ត្រីជាប់ឆ្នោតជាតំណាងរាស្ត្រសំរាប់នីតិកាលទី៥ ដែលមិនអាចសម្រេចតាមគោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជានៅចំណុចដៅទី ៣.៨ នៃគោលដៅទី៣ ដែលបានកំណត់ថា ***បង្កើនឲ្យមានតំណាងស្ត្រី ៣០% ក្នុងស្ថាប័នរដ្ឋសភាត្រឹមឆ្នាំ២០១៥*** និងកំណែទម្រង់រដ្ឋបាល រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈស្ដីអំពីការកំណត់កូតាពី ២០%-៥០% សម្រាប់ស្ត្រីក្នុងការជ្រើសរើសមន្ត្រីរាជការឲ្យចូលបម្រើការងារនៅក្នុងស្ថាប័នសាធារណៈនានា រួមទាំង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិទី២ (២០០៦-២០១០) បានកំណត់ថា "រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តលើកតម្កើងតួនាទីរបស់ស្ត្រីនៅក្នុងការធ្វើសេចក្ដីសម្រេចចិត្ត និងយកចិត្តទុកដាក់លើការបណ្ដុះបណ្ដាលជំនាញដល់ស្ត្រីនៅគ្រប់កម្រិត។

យោងតាមលទ្ធផលបឋមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ .ជ.ប) ចេញផ្សាយថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣ បានបង្ហាញឲ្យឃើញថាក្នុងចំណោមគណបក្សនយោបាយដែលបានចូលរួមប្រកួតប្រជែងទាំង៨ មានតែគណបក្សនយោបាយចំនួន០២ ប៉ុណ្ណោះដែលមានសំលេងឆ្នោតគាំទ្រច្រើន និងទទួលបានអាសនៈនៅរដ្ឋសភា គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ។ រីឯលទ្ធផលក្រៅផ្លូវការរបស់អង្គការខុមហ្វ្រែលកាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៣ បានរកឃើញ ថាស្ត្រីជាប់ឆ្នោតជាសមាជិកសភាមានចំនួនតែ **១៦រូប ស្មើនឹង ១៣%** នៃចំនួនអ្នកជាប់ឆ្នោតស្ត្រី-បុរសសរុប **១២៣រូប** ក្នុងនោះគណបក្សប្រជាជនកម្ពុជាមានចំនួន **៩រូប** និងគណបក្សសង្គ្រោះជាតិ មានចំនួន **៧ រូប** ។ តួលេខនេះ បានបង្ហាញឲ្យឃើញថាចំនួនស្ត្រីជាប់ឆ្នោតមានការថយចុះ **១,៦៣%** ពី **១៤,៦៣%** នៅនីតិកាលទី៤ ឆ្នាំ២០០៨ (ជាប់ឆ្នោតភ្លាម) មក **១៣%** នៅ នីតិកាលទី៥ ឆ្នាំ២០១៣ និងមានការថយចុះចំនួន **៨,១៣%** បើធៀបនឹងចុងនីតិកាលទី៤ ស្មើនឹង **២១,១៣ %**។

ដើម្បីឈានទៅសម្រេចតាមគោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា ក្រុមការងារស្ត្រីដើម្បីទាំងអស់គ្នាសូមជូនជាយោបល់ទៅរាជរដ្ឋាភិបាល និងគណបក្សនយោបាយទាំងអស់នូវចំណុចមួយចំនួនដូចខាងក្រោម៖

១- រដ្ឋាភិបាល និងគណបក្សនយោបាយត្រូវដាក់បញ្ចូល ***បេក្ខជនស្ត្រីដែលនៅលេខរៀងខាងក្រោម ឬបេក្ខជនស្ត្រីបម្រុង*** ឲ្យបានជាប់ជាតំណាងរាស្ត្រសំរាប់នីតិកាលទី៥នេះ នៅពេលដែល**អ្នកជាប់ឆ្នោតជាបុរស**ទៅកាន់តំណែងក្នុងរដ្ឋាភិបាល ឬលាលែងចេញពីតំណែង។

២- រដ្ឋាភិបាល និងគណបក្សនយោបាយត្រូវដាក់បញ្ចូល ***បេក្ខជនស្ត្រីដែលនៅលេខរៀងខាងក្រោម ឬបេក្ខជនស្ត្រីបម្រុង*** ឲ្យបានជាប់ជាតំណាងរាស្ត្រសំរាប់នីតិកាលទី៥នេះ នៅពេលដែល**អ្នកជាប់ឆ្នោតជាស្ត្រី**ទៅកាន់តំណែងក្នុងរដ្ឋាភិបាល ឬលាលែងចេញពីតំណែង។

៣- រាជរដ្ឋាភិបាលត្រូវតែ ***បង្កើនចំនួនស្ត្រីជាថ្នាក់ដឹកនាំ និងតួនាទីធ្វើសេចក្ដីសម្រេចនៅក្នុងក្រសួង ស្ថាប័ននីមួយៗ*** ដោយគិតចាប់ពីតួនាទីអនុរដ្ឋលេខាធិការ រដ្ឋលេខាធិការ រដ្ឋមន្ត្រី និងឧបនាយករដ្ឋមន្ត្រីឲ្យបានយ៉ាងតិច **៣០%**ដើម្បីឆ្លើយតបទៅតាមកំណែទម្រង់រដ្ឋបាលរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈនិងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។

ព័ត៌មានលំអិតសូមទំនាក់ទំនង៖


១) លោកស្រី ***សឺនរេគ សិរីលក្ខណ៍*** អ្នកសម្របសម្រួលកម្មវិធីអប់រំ និងយេនឌ័រអង្គការខុមហ្វ្រែល លេខទូរស័ព្ទ (៨៥៥)-១៧ ៤៩៤ ០០៤ អ៊ីម៉ែល sereyleak@comfrel.org

២) លោកស្រី **អរុណា រស្មី** នាយិកាអង្គការស្ត្រីខ្មែរ លេខទូរស័ព្ទ (៨៥៥) -១២ ២៣៦ ៦៥៣ អ៊ីម៉ែល strey_khmer@yahoo.com

៣) លោកស្រី **ម៉ែន វណ្ណាទី** អ្នកសម្របសម្រួលកម្មវិធី នៃគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ លេខទូរស័ព្ទ (៨៥៥)-១៦ ៩៤៩ ៩៩៧ អ៊ីម៉ែល pc@cpwp.net